20.04.23
F0957

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
លេខ.....០១៩.........អ.ស.ហ.ប្រក

# ប្រកាស
## ស្តីពី
## ការគ្រប់គ្រងអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត/ ០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២២/០០៣ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញអនុក្រឹត្យលេខ ៧៩ អនក្រ.បក ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២០ ស្តីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម
- បានឃើញប្រកាសលេខ ០០៧ អ.ស.ហ.ប្រក.ចុះថ្ងៃទី១ ខែតុលា ឆ្នាំ២០២១ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទរបស់និយ័តករគណនេយ្យនិងសវនកម្ម



#១៦៨F ផ្លូវលេខ ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
#168F, St. 598, Chrang Chamres 1, Russei Keo, Phnom Penh
Website: fsa.gov.kh, Telegram: t.me/fsacambodia
ទូរស័ព្ទ: (+៨៥៥) ២៣ ៩៩០ ៧០០
Phone: (+855) 23 990 700
info@fsa.gov.kh

- យោងតាមការអនុម័តនៃសម័យប្រជុំរបស់ក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ នាថ្ងៃទី៤ ខែមេសា ឆ្នាំ២០២៣

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១ ._**

ប្រកាសនេះ កំណត់លក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ ការបន្តសុពលភាព ការព្យួរ និងការដកហូតអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម ព្រមទាំងកំណត់សិទ្ធិនិងកាតព្វកិច្ចពាក់ព័ន្ធរបស់ម្ចាស់អាជ្ញាបណ្ណ សម្រាប់ការគ្រប់គ្រងការប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម ប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ដោយអនុលោមតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

**ប្រការ២ ._**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះបុគ្គលដែលប្រកបវិជ្ជាជីវៈគណនេយ្យ និង/ឬ សវនកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣ ._**

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់ក្នុងប្រកាសនេះ ត្រូវបានកំណត់ដូចខាងក្រោម÷

- **នីតិបុគ្គល** សំដៅដល់ក្រុមហ៊ុនដែលបង្កើតឡើងស្របតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា និងបទប្បញ្ញត្តិ ជាធរមាន។
- **បុគ្គល** សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមានកំណត់នៅក្នុងប្រកាសនេះ។
- **ម្ចាស់អាជ្ញាបណ្ណ** សំដៅដល់បុគ្គលដែលទទួលបានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ ឬសវនកម្មពីនិយ័តករគណនេយ្យនិងសវនកម្ម (**ន.គ.ស.**)។
- **រូបវន្តបុគ្គល** សំដៅដល់សមាជិកសកម្ម ឬសមាជិកចូលរួម ឬសមាជិកសមាគត របស់វិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា (**វ.គ.ស.ក.**)។
- **សេវាគណនេយ្យ** សំដៅដល់សេវានៃការកត់ត្រា ការចាត់ថ្នាក់ ការវាស់វែង ការផ្តុំបញ្ចូលនៃរបាយការណ៍ហិរញ្ញវត្ថុ ការបង្ហាញព័ត៌មានហិរញ្ញវត្ថុ រួមបញ្ចូលទាំងសេវាពិនិត្យគណនេយ្យ ការបញ្ជាក់សេវារៀបចំរបាយការណ៍ហិរញ្ញវត្ថុគំរូ និងសេវាប្រហាក់ប្រហែលផ្សេងទៀត រួមទាំងសេវាជម្រះបញ្ជីក្រុមហ៊ុន។
- **សេវាសវនកម្ម** សំដៅដល់សេវាត្រួតពិនិត្យនិងវាយតម្លៃដោយឯករាជ្យ និងជាប្រព័ន្ធលើទិន្នន័យរបាយការណ៍ កំណត់ត្រា កិច្ចប្រតិបត្តិការ និងលទ្ធផលជាហិរញ្ញវត្ថុ ឬមិនមែនហិរញ្ញវត្ថុរបស់អង្គភាពសម្រាប់គោលបំណងជាក់លាក់មួយដោយអនុលោមតាមស្តង់ដាទាក់ទងនឹងសវនកម្ម និងស្តង់ដាការអះអាងអន្តរជាតិនៃកម្ពុជា ដែលដាក់ចេញដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ជាធរមាន។

- **អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ** សំដៅដល់ការអនុញ្ញាតដើម្បីផ្តល់សេវាគណនេយ្យ សេវាជម្រះបញ្ជីក្រុមហ៊ុន និង/ឬ សេវាប្រហាក់ប្រហែលផ្សេងទៀតទៅតាមកម្រិតដែលបានកំណត់នៅក្នុងប្រការ៦ និងប្រការ១១ នៃប្រកាសនេះ។
- **អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្ម** សំដៅដល់ការអនុញ្ញាតដើម្បីផ្តល់សេវាសវនកម្ម សេវាគណនេយ្យ និង/ឬ សេវាជម្រះបញ្ជីក្រុមហ៊ុន។

## ជំពូកទី២
## អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម

**ប្រការ៤ ._**

បុគ្គលដែលអាចប្រកបវិជ្ជាជីវៈគណនេយ្យ ឬសវនកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជាបានលុះត្រាតែទទួលបានអាជ្ញាបណ្ណពី **ន.គ.ស.**។

មានតែនីតិបុគ្គលប៉ុណ្ណោះ ទើបមាននីតិសម្បទាប្រកបវិជ្ជាជីវៈគណនេយ្យ និង/ឬសវនកម្មបាន។ ដើម្បីទទួលបានអាជ្ញាបណ្ណ នីតិបុគ្គលនិងរូបវន្តបុគ្គល ត្រូវគោរពតាមលក្ខខណ្ឌដូចមានកំណត់នៅក្នុងប្រកាសនេះ។

អាជ្ញាបណ្ណត្រូវបានបែងចែកចេញជាពីរប្រភេទ គឺអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ និងអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្ម។

### ផ្នែកទី១
### អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ

**ប្រការ៥ ._**

អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ ត្រូវបានបែងចែកជា២(ពីរ)កម្រិត÷
- អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យកម្រិត១ និង
- អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យកម្រិត២។

**ប្រការ៦ ._**

អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យកម្រិត១ អាចផ្តល់សេវារួមមាន÷
- ការកត់ត្រាប្រតិបត្តិការគណនេយ្យ
- ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ
- ការផ្តល់ប្រឹក្សាគណនេយ្យ
- ការពិនិត្យបញ្ជីគណនេយ្យ និង
- ការផ្តល់សេវាគណនេយ្យប្រហាក់ប្រហែលផ្សេងទៀតដែលកំណត់ដោយ **ន.គ.ស.**។

**ប្រការ៧ ._**

នីតិបុគ្គលទាំងឡាយណាដែលមានបំណងប្រកបវិជ្ជាជីវៈគណនេយ្យកម្រិត១ ត្រូវដាក់ពាក្យស្នើសុំមក **ន.គ.ស.** និងត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម÷
- បានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា

- មានម្ចាស់ភាគហ៊ុនរូបវន្តបុគ្គល យ៉ាងតិច១(មួយ)រូប ជាសមាជិកសកម្មជាគណនេយ្យករជំនាញរបស់ **វ.គ.ស.ក.** និងកាន់កាប់ភាគហ៊ុនយ៉ាងតិច៥១%(ហាសិបមួយភាគរយ)។ ករណីមានម្ចាស់ភាគហ៊ុនជានីតិបុគ្គល ម្ចាស់ភាគហ៊ុននោះត្រូវចុះបញ្ជីនៅក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា និងមានសមាសភាពក្រុមប្រឹក្សាភិបាលយ៉ាងតិច៥០%បូក១(ហាសិបភាគរយបូកមួយ) ជាសមាជិកសកម្មរបស់ **វ.គ.ស.ក.**។
- បានចុះបញ្ជីនៅអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- មានកម្មវត្ថុអាជីវកម្មចម្បង ផ្តល់សេវាគណនេយ្យ
- មានផែនការអាជីវកម្ម រយៈពេល២(ពីរ)ឆ្នាំ យ៉ាងតិច
- មានរចនាសម្ព័ន្ធគ្រប់គ្រងច្បាស់លាស់ និងមានធនធានមនុស្សសមស្រប
- បានបំពេញលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវនិងសមស្រប តាមរយៈការបំពេញទម្រង់ឯកសារដែលកំណត់ដោយ **ន.គ.ស.**
- បំពេញលក្ខខណ្ឌផ្សេងទៀតតាមការតម្រូវរបស់ **ន.គ.ស.**។

**ប្រការ៨ ._**

នីតិបុគ្គលស្នើសុំ ត្រូវបំពេញពាក្យស្នើសុំតាមទម្រង់ដែលកំណត់ដោយ **ន.គ.ស.** និងភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម÷

- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម
- លក្ខន្តិកៈក្រុមហ៊ុន
- បណ្ណពន្ធប៉ាតង់ ឬបង្កាន់ដៃបង់ប្រាក់ពន្ធប៉ាតង់
- វិញ្ញាបនបត្របញ្ជាក់ជាសមាជិកសកម្ម ដែលចេញដោយ **វ.គ.ស.ក.** (ច្បាប់ថតចម្លងមានបញ្ជាក់ភាពត្រឹមត្រូវ)
- ផែនការអាជីវកម្មរយៈពេល២(ពីរ)ឆ្នាំ យ៉ាងតិច
- ឯកសារពាក់ព័ន្ធផ្សេងទៀតតាមការស្នើសុំរបស់ **ន.គ.ស.**។

**ប្រការ៩ ._**

រូបវន្តបុគ្គលស្នើសុំ ដែលជាម្ចាស់ភាគហ៊ុនរបស់នីតិបុគ្គល ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម÷

- ជាសមាជិកសកម្មជាគណនេយ្យករជំនាញរបស់ **វ.គ.ស.ក.**
- មានសញ្ជាតិខ្មែរ
- មិនមានជាប់ពាក់ព័ន្ធនឹងការងារផ្សេងក្នុងតួនាទីប្រតិបត្តិជាអ្នកដឹកនាំ អ្នកគ្រប់គ្រង អ្នកចាត់ចែង ឬតួនាទីប្រតិបត្តិប្រហាក់ប្រហែលក្នុងអង្គភាពដទៃ
- មិនមានជាប់ពាក់ព័ន្ធនឹងផលប្រយោជន៍ដោយផ្ទាល់ ឬប្រយោលនៅក្នុងក្រុមហ៊ុនគណនេយ្យ និង/ឬក្រុមហ៊ុនសវនកម្មដទៃ
- មិនធ្លាប់ប្រព្រឹត្តបំពានទៅនឹងក្រមសីលធម៌វិជ្ជាជីវៈ ក្នុងរយៈពេល៣(បី)ឆ្នាំ ចុងក្រោយ
- មិនធ្លាប់មានទោសឧក្រិដ្ឋ

- បានបំពេញលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវនិងសមស្រប តាមរយៈការបំពេញទម្រង់ឯកសារដែលកំណត់ដោយ **ន.គ.ស.**
- បំពេញលក្ខខណ្ឌផ្សេងទៀតតាមការតម្រូវរបស់ **ន.គ.ស.**។

**ប្រការ១០ ._**

រូបវន្តបុគ្គលស្នើសុំ ត្រូវបំពេញពាក្យស្នើសុំតាមទម្រង់ដែលកំណត់ដោយ **ន.គ.ស.** និងភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម÷

- វិញ្ញាបនបត្របញ្ជាក់ជាសមាជិកសកម្ម ដែលចេញដោយ **វ.គ.ស.ក.** (ច្បាប់ថតចម្លងមានបញ្ជាក់ភាពត្រឹមត្រូវ)
- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ (ច្បាប់ថតចម្លងមានបញ្ជាក់ភាពត្រឹមត្រូវ)
- លិខិតបញ្ជាក់បទពិសោធន៍ការងារពាក់ព័ន្ធគណនេយ្យ ដែលចេញដោយនិយោជក និងប្រវត្តិរូបសង្ខេប
- លិខិតបញ្ជាក់ពី **វ.គ.ស.ក.** អំពីក្រមសីលធម៌វិជ្ជាជីវៈល្អ
- លិខិតថ្កោលទោសច្បាប់ដើមមានសុពលភាពដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច
- ឯកសារពាក់ព័ន្ធផ្សេងទៀតតាមការស្នើសុំរបស់ **ន.គ.ស.**។

**ប្រការ១១ ._**

អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យកម្រិត២ អាចផ្តល់សេវាគណនេយ្យ មិនលើសពីសេវាខាងក្រោម÷

- ការកត់ត្រាប្រតិបត្តិការគណនេយ្យ
- ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងសេវាគណនេយ្យប្រហាក់ប្រហែលផ្សេងទៀត ដែលត្រូវកំណត់ដោយ **ន.គ.ស.**។

**ប្រការ១២ ._**

នីតិបុគ្គលទាំងឡាយណាដែលមានបំណងប្រកបវិជ្ជាជីវៈគណនេយ្យកម្រិត២ ត្រូវដាក់ពាក្យស្នើសុំមក **ន.គ.ស.** និងត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម÷

- បានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា
- មានម្ចាស់ភាគហ៊ុនរូបវន្តបុគ្គល យ៉ាងតិច១(មួយ)រូប ជាសមាជិកចូលរួម ឬសមាជិកសមាគតរបស់ **វ.គ.ស.ក.** និងកាន់កាប់ភាគហ៊ុន យ៉ាងតិច៥១%(ហាសិបមួយភាគរយ)។ ករណីមានម្ចាស់ភាគហ៊ុនជានីតិបុគ្គល ម្ចាស់ភាគហ៊ុន នោះត្រូវចុះបញ្ជីនៅក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា និងមានសមាសភាពក្រុមប្រឹក្សាភិបាល យ៉ាងតិច៥០%បូក១(ហាសិបភាគរយបូកមួយ) ជាសមាជិកចូលរួម ឬសមាជិកសមាគតរបស់ **វ.គ.ស.ក.**
- បានចុះបញ្ជីនៅអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- មានកម្មវត្ថុអាជីវកម្មចម្បង ផ្តល់សេវាគណនេយ្យ
- មានផែនការអាជីវកម្ម រយៈពេល២(ពីរ)ឆ្នាំ យ៉ាងតិច
- មានរចនាសម្ព័ន្ធគ្រប់គ្រងច្បាស់លាស់ និងមានធនធានមនុស្សសមស្រប

- បានបំពេញលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវនិងសមស្រប តាមរយៈការបំពេញទម្រង់ឯកសារដែលកំណត់ដោយ **ន.គ.ស.**
- បំពេញលក្ខខណ្ឌផ្សេងទៀតតាមការតម្រូវរបស់ **ន.គ.ស.**។

**ប្រការ១៣ ._**

នីតិបុគ្គលស្នើសុំ ត្រូវបំពេញពាក្យស្នើសុំតាមទម្រង់ដែលកំណត់ដោយ **ន.គ.ស.** និងភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម÷

- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម
- លក្ខន្តិកៈក្រុមហ៊ុន
- បណ្ណពន្ធប៉ាតង់ ឬបង្កាន់ដៃបង់ប្រាក់ពន្ធប៉ាតង់
- វិញ្ញាបនបត្របញ្ជាក់ជាសមាជិកចូលរួម ឬសមាជិកសមាគត ដែលចេញដោយ **ទ.គ.ស.ក.** (ច្បាប់ថតចម្លងមានបញ្ជាក់ភាពត្រឹមត្រូវ)
- ផែនការអាជីវកម្ម រយៈពេល២(ពីរ)ឆ្នាំ យ៉ាងតិច
- ឯកសារពាក់ព័ន្ធផ្សេងទៀតតាមការស្នើសុំរបស់ **ន.គ.ស.**។

**ប្រការ១៤ ._**

រូបវន្តបុគ្គលស្នើសុំ ដែលជាម្ចាស់ភាគហ៊ុនរបស់នីតិបុគ្គល ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម÷

- ជាសមាជិកចូលរួម ឬសមាជិកសមាគត របស់ **ទ.គ.ស.ក.**
- មានសញ្ជាតិខ្មែរ
- មិនមានជាប់ពាក់ព័ន្ធនឹងការងារផ្សេងក្នុងតួនាទីប្រតិបត្តិជាអ្នកដឹកនាំ អ្នកគ្រប់គ្រង អ្នកចាត់ចែង ឬតួនាទីប្រតិបត្តិប្រហាក់ប្រហែលក្នុងអង្គភាពដទៃ
- មិនមានជាប់ពាក់ព័ន្ធនឹងផលប្រយោជន៍ដោយផ្ទាល់ ឬប្រយោលនៅក្នុងក្រុមហ៊ុនគណនេយ្យ និង/ឬក្រុមហ៊ុនសវនកម្មដទៃ
- មិនធ្លាប់ប្រព្រឹត្តបំពានទៅនឹងក្រមសីលធម៌វិជ្ជាជីវៈ ក្នុងរយៈពេល៣(បី)ឆ្នាំ ចុងក្រោយ
- មិនធ្លាប់មានទោសឧក្រិដ្ឋ
- បានបំពេញលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវនិងសមស្រប តាមរយៈការបំពេញទម្រង់ឯកសារដែលកំណត់ដោយ **ន.គ.ស.**
- បំពេញលក្ខខណ្ឌផ្សេងទៀតតាមការតម្រូវរបស់ **ន.គ.ស.**។

**ប្រការ១៥ ._**

រូបវន្តបុគ្គលស្នើសុំ ត្រូវបំពេញពាក្យស្នើសុំតាមទម្រង់ដែលកំណត់ដោយ **ន.គ.ស.** និងភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម÷

- វិញ្ញាបនបត្របញ្ជាក់ជាសមាជិកចូលរួម ឬសមាជិកសមាគត ដែលចេញដោយ **ទ.គ.ស.ក.** (ច្បាប់ថតចម្លងមានបញ្ជាក់ភាពត្រឹមត្រូវ)

- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ (ច្បាប់ថតចម្លងមានបញ្ជាក់ភាពត្រឹមត្រូវ)
- លិខិតបញ្ជាក់បទពិសោធន៍ការងារពាក់ព័ន្ធគណនេយ្យ ដែលចេញដោយនិយោជក និងប្រវត្តិរូបសង្ខេប
- លិខិតបញ្ជាក់ពី **វ.គ.ស.ក.** អំពីក្រមសីលធម៌វិជ្ជាជីវៈល្អ
- លិខិតថ្កោលទោសច្បាប់ដើមមានសុពលភាពដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច
- ឯកសារពាក់ព័ន្ធផ្សេងទៀតតាមការស្នើសុំរបស់ **ន.គ.ស.**។

## ផ្នែកទី២
## អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្ម

**ប្រការ១៦ .-**

នីតិបុគ្គលដែលទទួលបានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្ម មាននីតិសម្បទាផ្តល់សេវាសវនកម្មនិងគណនេយ្យដោយស្វ័យប្រវត្តិ។

នីតិបុគ្គលទាំងឡាយណាដែលមានបំណងប្រកបវិជ្ជាជីវៈសវនកម្ម ត្រូវដាក់ពាក្យស្នើសុំមក **ន.គ.ស.** និងត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម÷

- បានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា
- មានម្ចាស់ភាគហ៊ុនរូបវន្តបុគ្គល យ៉ាងតិច១(មួយ)រូប ជាសមាជិកសកម្មជាសវនករប្រតិស្រុតរបស់ **វ.គ.ស.ក.** និងកាន់កាប់ភាគហ៊ុន យ៉ាងតិច៥១%(ហាសិបមួយភាគរយ)។ ករណីមានម្ចាស់ភាគហ៊ុនជានីតិបុគ្គល ម្ចាស់ភាគហ៊ុននោះត្រូវចុះបញ្ជីនៅក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា និងមានសមាសភាពក្រុមប្រឹក្សាភិបាល យ៉ាងតិច៥០%បូក១(ហាសិបភាគរយបូកមួយ) ជាសមាជិកសកម្មរបស់ **វ.គ.ស.ក.**
- មានកម្មវត្ថុអាជីវកម្មចម្បង ផ្តល់សេវាសវនកម្ម
- បានចុះបញ្ជីនៅអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- មានធានារ៉ាប់រងវិជ្ជាជីវៈសមស្រប
- មានផែនការអាជីវកម្ម រយៈពេល២(ពីរ)ឆ្នាំ យ៉ាងតិច
- មានរចនាសម្ព័ន្ធគ្រប់គ្រងច្បាស់លាស់ និងមានធនធានមនុស្សសមស្រប
- បានបំពេញលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវនិងសមស្រប តាមរយៈការបំពេញទម្រង់ឯកសារដែលកំណត់ដោយ **ន.គ.ស.**
- បំពេញលក្ខខណ្ឌផ្សេងទៀតតាមការតម្រូវរបស់ **ន.គ.ស.**។

**ប្រការ១៧ .-**

នីតិបុគ្គលស្នើសុំ ត្រូវបំពេញពាក្យស្នើសុំតាមទម្រង់ដែលកំណត់ដោយ **ន.គ.ស.** និងភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម÷

- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម
- លក្ខន្តិកៈក្រុមហ៊ុន

- បណ្ណពន្ធប៉ាតង់ ឬបង្កាន់ដៃបង់ប្រាក់ពន្ធប៉ាតង់
- វិញ្ញាបនបត្របញ្ជាក់ជាសមាជិកសកម្ម ដែលចេញដោយ **ទ.គ.ស.ក.** (ច្បាប់ថតចម្លងមានបញ្ជាក់ភាពត្រឹមត្រូវ)
- វិញ្ញាបនបត្រធានារ៉ាប់រងវិជ្ជាជីវៈ
- ផែនការអាជីវកម្ម រយៈពេល២(ពីរ)ឆ្នាំ យ៉ាងតិច
- ឯកសារពាក់ព័ន្ធផ្សេងទៀតតាមការស្នើសុំរបស់ **ន.គ.ស.**។

**ប្រការ១៨**._

រូបវន្តបុគ្គលស្នើសុំ ដែលជាម្ចាស់ភាគហ៊ុនរបស់នីតិបុគ្គល ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម÷

- ជាសមាជិកសកម្មជាសវនករប្រតិស្រុតរបស់ **ទ.គ.ស.ក.**
- មានសញ្ជាតិខ្មែរ
- បានឆ្លងកាត់ការប្រឡងនិងប្រឡងជាប់លើមុខវិជ្ជាគុណភាពសវនកម្ម
- មិនមានជាប់ពាក់ព័ន្ធនឹងការងារផ្សេងក្នុងតួនាទីប្រតិបត្តិជាអ្នកដឹកនាំ អ្នកគ្រប់គ្រង អ្នកចាត់ចែង ឬតួនាទីប្រតិបត្តិប្រហាក់ប្រហែលក្នុងអង្គភាពដទៃ
- មិនមានជាប់ពាក់ព័ន្ធនឹងផលប្រយោជន៍ដោយផ្ទាល់ ឬប្រយោលនៅក្នុងក្រុមហ៊ុនគណនេយ្យ និង/ឬ សវនកម្មដទៃ
- មិនធ្លាប់ប្រព្រឹត្តបំពានទៅនឹងក្រមសីលធម៌វិជ្ជាជីវៈ ក្នុងរយៈពេល ៣(បី)ឆ្នាំ ចុងក្រោយ
- មិនធ្លាប់មានទោសឧក្រិដ្ឋ
- បានបំពេញលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវនិងសមស្រប តាមរយៈការបំពេញទម្រង់ឯកសារដែលកំណត់ដោយ **ន.គ.ស.**
- បំពេញលក្ខខណ្ឌផ្សេងទៀត តាមការចាំបាច់ការតម្រូវរបស់ **ន.គ.ស.**។

**ប្រការ១៩**._

រូបវន្តបុគ្គលស្នើសុំ ត្រូវបំពេញពាក្យស្នើសុំតាមទម្រង់ដែលកំណត់ដោយ **ន.គ.ស.** និងភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម÷

- វិញ្ញាបនបត្របញ្ជាក់ជាសមាជិកសកម្ម ដែលចេញដោយ **ទ.គ.ស.ក.** (ច្បាប់ថតចម្លងមានបញ្ជាក់ភាពត្រឹមត្រូវ)
- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ (ច្បាប់ថតចម្លងមានបញ្ជាក់ភាពត្រឹមត្រូវ)
- លទ្ធផលប្រឡងលើមុខវិជ្ជាគុណភាពសវនកម្ម
- លិខិតបញ្ជាក់បទពិសោធន៍ការងារពាក់ព័ន្ធសវនកម្ម ចេញដោយនិយោជក និងប្រវត្តិរូបសង្ខេប
- លិខិតបញ្ជាក់ពី **ទ.គ.ស.ក.** ពីក្រមសីលធម៌វិជ្ជាជីវៈល្អ
- លិខិតថ្កោលទោសច្បាប់ដើមមានសុពលភាពដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច
- ឯកសារពាក់ព័ន្ធផ្សេងទៀតតាមការស្នើសុំរបស់ **ន.គ.ស.**។

## ផ្នែកទី ៣
## ការជម្រះបញ្ជី និងលក្ខខណ្ឌតម្រូវ

**ប្រការ២០ ._**

នីតិបុគ្គលដែលមានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យកម្រិត១ ឬអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្ម ទទួលបាននីតិសម្បទាក្នុងការផ្តល់សេវាជម្រះបញ្ជី ដោយត្រូវបំពេញលក្ខខណ្ឌតម្រូវបន្ថែម ដូចមានចែងក្នុង ប្រការ២១ នៃប្រកាសនេះ។

ការជម្រះបញ្ជីអាចធ្វើឡើងតាមផ្លូវតុលាការ ឬក្រៅប្រព័ន្ធតុលាការ។

**ប្រការ២១ ._**

នីតិបុគ្គលដែលផ្តល់សេវាការជម្រះបញ្ជី ត្រូវមានមេធាវីដែលជាសមាជិករបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចំនួន១(មួយ)រូប យ៉ាងតិច ឬមានអនុស្សារណៈនៃការយោគយល់គ្នាជាមួយការិយាល័យមេធាវីស្របច្បាប់។

**ប្រការ២២ ._**

តួនាទី សិទ្ធិអំណាច និងការទទួលខុសត្រូវរបស់អ្នកជម្រះបញ្ជី មានកំណត់នៅក្នុងច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

**ប្រការ២៣ ._**

នីតិបុគ្គលដែលទទួលសេវាជម្រះបញ្ជីពីអតិថិជន មានកាតព្វកិច្ចរក្សាទុកនូវបញ្ជីគណនេយ្យនិងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនដែលរំលាយ ហើយបានប្រើសេវាជម្រះបញ្ជីរបស់ខ្លួន រយៈពេលយ៉ាងតិច៥(ប្រាំ)ឆ្នាំ ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី៣
## លក្ខខណ្ឌនៃការបន្តអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម

**ប្រការ២៤ ._**

នីតិបុគ្គលដែលប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម ត្រូវទទួលបានការបន្តអាជ្ញាបណ្ណពី **ន.គ.ស.**។

## ផ្នែកទី១
## លក្ខខណ្ឌសម្រាប់ការបន្តអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ និងឯកសារភ្ជាប់

**ប្រការ២៥ ._**

នីតិបុគ្គលទាំងឡាយណា ដែលមានបំណងសុំបន្តអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ ត្រូវដាក់ពាក្យស្នើសុំ និងត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម÷

- បានបំពេញកាតព្វកិច្ចត្រឹមត្រូវ ស្របតាមប្រការ៣៦ នៃប្រកាសនេះ
- មិនធ្លាប់មានបណ្តឹងបរិហារពីកំហុសធ្ងន់ធ្ងរ និងមិនធ្លាប់មានសេចក្តីសម្រេចរបស់អាជ្ញាធរមានសមត្ថកិច្ចណាមួយថាពិតជាមានកំហុស

- បានបំពេញលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវនិងសមស្រប តាមរយៈការបំពេញទម្រង់ឯកសារដែលកំណត់ដោយ **ន.គ.ស.**
- មានរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទគណនេយ្យ រយៈពេល២(ពីរ)ឆ្នាំ ចុងក្រោយដោយអនុលោមតាមស្តង់ដាគណនេយ្យនិងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន
- មានគម្រោងថវិកាប្រចាំឆ្នាំ
- បានបង់ប្រាក់សម្រាប់ថ្លៃពាក្យស្នើសុំនិងសោហ៊ុយសិក្សាសំណុំឯកសារ និងកម្រៃអាជ្ញាបណ្ណក្រោយទទួលបានការឯកភាពជាគោលការណ៍ពី **ន.គ.ស.**
- បំពេញលក្ខខណ្ឌផ្សេងទៀតតាមការតម្រូវរបស់ **ន.គ.ស.**។

**ប្រការ២៦ ._**

នីតិបុគ្គលស្នើសុំបន្ត ត្រូវបំពេញពាក្យស្នើសុំតាមទម្រង់ដែលកំណត់ដោយ **ន.គ.ស.** ក្នុងរយៈពេល៤៥(សែសិបប្រាំ)ថ្ងៃ យ៉ាងតិច មុនអាជ្ញាបណ្ណចាស់អស់សុពលភាព និងភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម÷

- របាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទគណនេយ្យ២(ពីរ)ឆ្នាំ ចុងក្រោយ ដោយអនុលោមតាមស្តង់ដាគណនេយ្យ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន
- បង្កាន់ដៃបង់ប្រាក់បន្តអាជ្ញាបណ្ណ
- បណ្ណពន្ធប៉ាតង់ ឬបង្កាន់ដៃបង់ប្រាក់ពន្ធប៉ាតង់
- គម្រោងថវិកាប្រចាំឆ្នាំ
- ឯកសារពាក់ព័ន្ធផ្សេងទៀតតាមការស្នើសុំរបស់ **ន.គ.ស.**។

**ប្រការ២៧ ._**

រូបវន្តបុគ្គលស្នើសុំបន្ត ដែលជាម្ចាស់ភាគហ៊ុនរបស់នីតិបុគ្គល ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម÷

- មិនធ្លាប់ប្រព្រឹត្តបំពានទៅនឹងក្រមសីលធម៌វិជ្ជាជីវៈ
- បានបំពេញកាតព្វកិច្ចត្រឹមត្រូវ ស្របតាមប្រការ៣៦ នៃប្រកាសនេះ
- បានចូលរួមក្នុងកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈបន្តតាមចំនួនម៉ោង ដែលកំណត់ដោយ **ន.គ.ស.** និង **វ.គ.ស.ក.** សម្រាប់រយៈពេល១២(ដប់ពីរ)ខែ ចុងក្រោយ គិតត្រឹមថ្ងៃដាក់ពាក្យ
- មិនមានជាប់ពាក់ព័ន្ធនឹងការងារផ្សេងក្នុងតួនាទីប្រតិបត្តិជាអ្នកដឹកនាំ អ្នកគ្រប់គ្រង អ្នកចាត់ចែង ឬតួនាទីប្រតិបត្តិប្រហាក់ប្រហែលក្នុងអង្គភាពដទៃ
- មិនមានជាប់ពាក់ព័ន្ធនឹងផលប្រយោជន៍ដោយផ្ទាល់ ឬប្រយោលនៅក្នុងក្រុមហ៊ុនគណនេយ្យ និង/ឬ សវនកម្មដទៃទៀត
- បានបង់ប្រាក់សម្រាប់ថ្លៃពាក្យស្នើសុំនិងសោហ៊ុយសិក្សាសំណុំឯកសារ និងកម្រៃអាជ្ញាបណ្ណ ក្រោយទទួលបានការឯកភាពជាគោលការណ៍ពី **ន.គ.ស.**
- បានបំពេញលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវនិងសមស្រប តាមរយៈការបំពេញទម្រង់ឯកសារដែលកំណត់ដោយ **ន.គ.ស.**

- បំពេញលក្ខខណ្ឌផ្សេងទៀតតាមការតម្រូវរបស់ **ន.គ.ស.**។

**ប្រការ២៨ ._**

រូបវន្តបុគ្គលស្នើសុំបន្ត ត្រូវបំពេញពាក្យស្នើសុំតាមទម្រង់ដែលកំណត់ដោយ **ន.គ.ស.** ក្នុងរយៈពេល៤៥(សែសិបប្រាំ)ថ្ងៃ យ៉ាងតិច មុនអាជ្ញាបណ្ណចាស់អស់សុពលភាព និងភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម÷

- លិខិតបញ្ជាក់ពី **វ.គ.ស.ក.** អំពីក្រមសីលធម៌វិជ្ជាជីវៈល្អ
- លិខិតបញ្ជាក់ពី **ន.គ.ស.** និង **វ.គ.ស.ក.** អំពីការបំពេញកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈបន្តសម្រាប់រយៈពេល ១២(ដប់ពីរ)ខែ ចុងក្រោយ គិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំ
- លិខិតបញ្ជាក់បទពិសោធន៍ការងារពាក់ព័ន្ធគណនេយ្យ ចេញដោយនិយោជក និងប្រវត្តិរូបសង្ខេប
- លិខិតថ្កោលទោសច្បាប់ដើមមានសុពលភាពដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច
- បង្កាន់ដៃបង់ប្រាក់បន្តអាជ្ញាបណ្ណ
- ឯកសារពាក់ព័ន្ធផ្សេងទៀតតាមការស្នើសុំរបស់ **ន.គ.ស.**។

## ផ្នែកទី២

## លក្ខខណ្ឌនៃការបន្តអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្ម និងឯកសារភ្ជាប់

**ប្រការ២៩ ._**

នីតិបុគ្គលទាំងឡាយណាដែលមានបំណងសុំបន្តអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្ម ត្រូវដាក់ពាក្យស្នើសុំ និងត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម÷

- បានបំពេញកាតព្វកិច្ចត្រឹមត្រូវ ស្របតាមប្រការ៣៦ នៃប្រកាសនេះ
- ត្រូវមានរូបវន្តបុគ្គលដែលមានសិទ្ធិចុះហត្ថលេខា យ៉ាងតិច២(ពីរ)រូប ក្នុងក្រុមហ៊ុន ហើយក្នុងករណីមាន ១(មួយ)រូប ត្រូវមានអនុស្សារណៈយោគយល់គ្នាជាមួយនឹងក្រុមហ៊ុនសវនកម្មផ្សេងទៀត ដែលទម្រង់ និងខ្លឹមសារ ត្រូវមានការទទួលស្គាល់ពី **ន.គ.ស.**
- មានធានារ៉ាប់រងវិជ្ជាជីវៈសមស្រប
- ត្រូវមានយន្តការត្រួតពិនិត្យគុណភាពសវនកម្ម ដោយអនុលោមតាមស្តង់ដាទាក់ទងនឹងសវនកម្ម និង ស្តង់ដាការអះអាងអន្តរជាតិនៃកម្ពុជា ព្រមទាំងស្តង់ដាពាក់ព័ន្ធផ្សេងទៀត ដែលមានជាធរមាននៅក្នុង ព្រះរាជាណាចក្រកម្ពុជា
- មិនធ្លាប់មានបណ្តឹងបរិហារពីកំហុសធ្ងន់ធ្ងរ និងមិនធ្លាប់មានសេចក្តីសម្រេចរបស់អាជ្ញាធរមានសមត្ថកិច្ច ណាមួយថាពិតជាមានកំហុស
- បានបំពេញលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវនិងសមស្រប តាមរយៈការបំពេញទម្រង់ឯកសារដែលកំណត់ដោយ **ន.គ.ស.**
- មានរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទគណនេយ្យ២(ពីរ)ឆ្នាំ ចុងក្រោយ ដោយអនុលោមតាម ស្តង់ដាគណនេយ្យនិងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន
- មានគម្រោងថវិកាប្រចាំឆ្នាំ

- បានបង់ប្រាក់សម្រាប់ថ្លៃពាក្យស្នើសុំនិងសោហ៊ុយសិក្សាសំណុំឯកសារ និងកម្រៃអាជ្ញាបណ្ណ ក្រោយទទួលបានការឯកភាពជាគោលការណ៍ពី **ន.គ.ស.**
- បំពេញលក្ខខណ្ឌផ្សេងទៀតតាមការតម្រូវរបស់ **ន.គ.ស.**។

**ប្រការ៣០ ._**

នីតិបុគ្គលស្នើសុំបន្ត ត្រូវបំពេញពាក្យស្នើសុំតាមទម្រង់ដែលកំណត់ដោយ **ន.គ.ស.** ក្នុងរយៈពេល៤៥ (សែសិបប្រាំ)ថ្ងៃ យ៉ាងតិច មុនអាជ្ញាបណ្ណចាស់អស់សុពលភាព និងភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម÷

- របាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទគណនេយ្យ២(ពីរ)ឆ្នាំ ចុងក្រោយ ដោយអនុលោមតាមស្តង់ដាគណនេយ្យ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន
- វិញ្ញាបនបត្រធានារ៉ាប់រង
- គម្រោងថវិកាប្រចាំឆ្នាំ
- ឯកសារដែលបញ្ជាក់ពីយន្តការត្រួតពិនិត្យគុណភាពសវនកម្ម
- បង្កាន់ដៃបង់ប្រាក់បន្តអាជ្ញាបណ្ណ
- បណ្ណពន្ធប៉ាតង់ ឬបង្កាន់ដៃបង់ប្រាក់ពន្ធប៉ាតង់
- ឯកសារពាក់ព័ន្ធផ្សេងទៀតតាមការស្នើសុំរបស់ **ន.គ.ស.**។

**ប្រការ៣១ ._**

រូបវន្តបុគ្គលស្នើសុំបន្ត ដែលជាម្ចាស់ភាគហ៊ុនរបស់នីតិបុគ្គល ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម÷

- មិនធ្លាប់ប្រព្រឹត្តបំពានទៅក្រមសីលធម៌វិជ្ជាជីវៈ
- បានបំពេញកាតព្វកិច្ចត្រឹមត្រូវ ស្របតាមប្រការ៣៦ នៃប្រកាសនេះ
- បានចូលរួមក្នុងកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈបន្តតាមចំនួនម៉ោង ដែលកំណត់ដោយ **ន.គ.ស.** និង **វ.គ.ស.ក.** សម្រាប់រយៈពេល១២(ដប់ពីរ)ខែ ចុងក្រោយ គិតត្រឹមថ្ងៃដាក់ពាក្យ
- មិនមានជាប់ពាក់ព័ន្ធនឹងការងារផ្សេងក្នុងតួនាទីប្រតិបត្តិជាអ្នកដឹកនាំ អ្នកគ្រប់គ្រង អ្នកចាត់ចែង ឬតួនាទីប្រតិបត្តិប្រហាក់ប្រហែលក្នុងអង្គភាពដទៃ
- មិនមានជាប់ពាក់ព័ន្ធនឹងផលប្រយោជន៍ដោយផ្ទាល់ ឬប្រយោលនៅក្នុងក្រុមហ៊ុនគណនេយ្យ និង/ឬ សវនកម្ម ដទៃទៀត
- បានបង់ប្រាក់សម្រាប់ថ្លៃពាក្យស្នើសុំនិងសោហ៊ុយសិក្សាសំណុំឯកសារ និងកម្រៃអាជ្ញាបណ្ណក្រោយពីទទួលបានការឯកភាពជាគោលការណ៍ពី **ន.គ.ស.**
- បានបំពេញលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវនិងសមស្រប តាមរយៈការបំពេញទម្រង់ឯកសារដែលកំណត់ដោយ **ន.គ.ស.**
- បំពេញលក្ខខណ្ឌផ្សេងទៀតតាមការតម្រូវរបស់ **ន.គ.ស.**។

**ប្រការ៣២ ._**

រូបវន្តបុគ្គលស្នើសុំបន្ត ត្រូវបំពេញពាក្យស្នើសុំតាមទម្រង់ដែលកំណត់ដោយ **ន.គ.ស.** ក្នុងរយៈពេល៤៥ (សែសិបប្រាំ)ថ្ងៃ យ៉ាងតិច មុនអាជ្ញាបណ្ណចាស់អស់សុពលភាព និងភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម÷

- លិខិតបញ្ជាក់ពី **វ.គ.ស.ក.** អំពីក្រមសីលធម៌វិជ្ជាជីវៈល្អ
- លិខិតបញ្ជាក់ពី **ន.គ.ស.** និង **វ.គ.ស.ក.** អំពីការបំពេញកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈបន្ត សម្រាប់រយៈពេល ១២(ដប់ពីរ)ខែ ចុងក្រោយ គិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំ
- លិខិតបញ្ជាក់បទពិសោធន៍ការងារពាក់ព័ន្ធសវនកម្ម ចេញដោយនិយោជក និងប្រវត្តិរូបសង្ខេប
- លិខិតថ្កោលទោសច្បាប់ដើមមានសុពលភាពដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច
- បង្កាន់ដៃបង់ប្រាក់បន្តអាជ្ញាបណ្ណ
- ឯកសារពាក់ព័ន្ធផ្សេងទៀតតាមការស្នើសុំរបស់ **ន.គ.ស.**។

## ជំពូកទី៤
## បែបបទ និងនីតិវិធីនៃការផ្ដល់អាជ្ញាបណ្ណ និងការបន្តអាជ្ញាបណ្ណ
## ប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម

**ប្រការ៣៣ ._**

ដើម្បីទទួលបានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ ឬអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្ម បុគ្គលស្នើសុំត្រូវដាក់ពាក្យស្នើសុំមក **ន.គ.ស.** តាមទម្រង់ដែលកំណត់ដោយ **ន.គ.ស.** និងត្រូវភ្ជាប់សំណុំឯកសារតាមប្រភេទអាជ្ញាបណ្ណនីមួយៗដូចមានចែងក្នុងប្រកាសនេះ។

បុគ្គលស្នើសុំ ត្រូវបង់ថ្លៃពាក្យស្នើសុំនិងសោហ៊ុយសិក្សាសំណុំឯកសារ និងកម្រៃអាជ្ញាបណ្ណដូចមានចែងក្នុងប្រកាសនេះ។

ក្នុងរយៈពេល១៥(ដប់ប្រាំ )ថ្ងៃ ក្រោយទទួលបានឯកសារពេញលេញ **ន.គ.ស.** ត្រូវផ្ដល់ដំណឹងអំពីការផ្ដល់អាជ្ញាបណ្ណ ឬការមិនផ្ដល់អាជ្ញាបណ្ណ ជូនបុគ្គលស្នើសុំ។

**ប្រការ៣៤ ._**

ដើម្បីបន្តអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ ឬអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្ម ម្ចាស់អាជ្ញាបណ្ណត្រូវដាក់ពាក្យស្នើសុំមក **ន.គ.ស.** តាមទម្រង់ដែលកំណត់ដោយ **ន.គ.ស.** និងត្រូវភ្ជាប់សំណុំឯកសារសម្រាប់ប្រភេទអាជ្ញាបណ្ណ នីមួយៗ ដូចមានចែងក្នុងប្រកាសនេះ។

ម្ចាស់អាជ្ញាបណ្ណត្រូវបង់ថ្លៃពាក្យស្នើសុំនិងសោហ៊ុយសិក្សាសំណុំឯកសារ និងកម្រៃអាជ្ញាបណ្ណដូចមានចែងក្នុងប្រកាសនេះ។

ក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ ក្រោយទទួលបានឯកសារពេញលេញ **ន.គ.ស.** ត្រូវផ្ដល់ដំណឹងអំពីការបន្តអាជ្ញាបណ្ណ ឬការមិនបន្តអាជ្ញាបណ្ណ ជូនបុគ្គលស្នើសុំ។

## ជំពូកទី៥
## សិទ្ធិនិងភារកិច្ចរបស់ម្ចាស់អាជ្ញាបណ្ណ និងការហាមឃាត់

**ប្រការ៣៥ ._**

ម្ចាស់អាជ្ញាបណ្ណជានីតិបុគ្គល មានសិទ្ធិប្រើប្រាស់អាជ្ញាបណ្ណតាមកម្រិតនិងតាមប្រភេទនីមួយៗ ក្នុងការផ្ដល់សេវាគណនេយ្យ ឬសេវាសវនកម្មដោយស្របច្បាប់។

បន្ថែមលើនីតិសម្បទាខាងលើ ម្ចាស់អាជ្ញាបណ្ណជានីតិបុគ្គលមានសិទ្ធិធ្វើជាតំណាងឱ្យសហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ លើកិច្ចការដូចខាងក្រោម÷

- ធ្វើទំនាក់ទំនងជាមួយ **ន.គ.ស.**
- បំពេញបែបបទរដ្ឋបាលជាមួយ **ន.គ.ស.**
- ដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុមក **ន.គ.ស.**
- បង្ហាញនិងផ្តល់ឯកសារ របាយការណ៍ ឬលិខិតយុត្តិការផ្សេងៗពាក់ព័ន្ធនឹងកិច្ចការគណនេយ្យនិងសវនកម្មដល់ **ន.គ.ស.**
- ធ្វើបណ្តឹងតវ៉ា ស្របតាមបទប្បញ្ញត្តិពាក់ព័ន្ធគណនេយ្យនិងសវនកម្មជាធរមាន
- ទទួលព័ត៌មានជាប្រចាំអំពីការធ្វើបច្ចុប្បន្នភាពឬវិសោធកម្មនៃច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងគណនេយ្យនិងសវនកម្ម។

រាល់ការធ្វើជាតំណាងឱ្យសហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ ត្រូវមានលិខិតផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរ។

**ប្រការ៣៦ ._**

ម្ចាស់អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ ឬសវនកម្ម មានកាតព្វកិច្ចដូចខាងក្រោម÷

- គោរពឱ្យបានខ្ជាប់ខ្ជួននូវកាតព្វកិច្ចនានា ដូចបានកំណត់នៅក្នុងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន
- ត្រូវគោរព និងអនុវត្តតាមក្រមសីលធម៌វិជ្ជាជីវៈនិងស្តង់ដាបច្ចេកទេសពាក់ព័ន្ធជាធរមាន
- ត្រូវដាក់តាំងអាជ្ញាបណ្ណនៅក្នុងទីកន្លែងធ្វើការ ដែលសាធារណជនងាយស្រួលមើលឃើញ
- ផ្តល់របាយការណ៍ស្ថានភាពរបស់ក្រុមហ៊ុន ជាអាទិ៍ ចំនួនបុគ្គលិក និងទីតាំងការិយាល័យក្រុមហ៊ុន (ក្នុងករណីមានការប្រែប្រួលឬផ្លាស់ប្តូរ) មក **ន.គ.ស.** យ៉ាងយូរត្រឹមថ្ងៃទី២៥ ខែធ្នូ នៃឆ្នាំនីមួយៗ
- ផ្តល់របាយការណ៍ស្ថិតិលម្អិតនៃអតិថិជននិងរបាយការណ៍ផ្សេងទៀតប្រចាំឆមាសនិងប្រចាំឆ្នាំមក **ន.គ.ស.** តាមទម្រង់និងសេចក្តីណែនាំរបស់ **ន.គ.ស.**
- ត្រូវសុំគោលការណ៍អនុញ្ញាតជាមុនពី **ន.គ.ស.** លើការផ្លាស់ប្តូរព័ត៌មានក្រុមហ៊ុន ដែលប៉ះពាល់ដល់នីតិសម្បទានៃការប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម
- ជូនដំណឹងមក **ន.គ.ស.** ក្នុងរយៈពេល២០(ម្ភៃ)ថ្ងៃ នៃថ្ងៃធ្វើការក្រោយពីមានការផ្លាស់ប្តូរលក្ខន្តិកៈក្រុមហ៊ុន អាសយដ្ឋាន លេខទូរស័ព្ទ អ៊ីម៉ែល និងមធ្យោបាយទំនាក់ទំនងផ្សេងទៀត
- ត្រូវមានធានារ៉ាប់រងវិជ្ជាជីវៈប្រចាំឆ្នាំសមស្រប សម្រាប់អាជ្ញាបណ្ណសវនកម្ម
- ត្រូវផ្តល់របាយការណ៍តម្លាភាពប្រចាំឆ្នាំ ចំពោះសហគ្រាសទទួលខុសត្រូវជាសាធារណៈ មក **ន.គ.ស.** យ៉ាងយូរត្រឹមថ្ងៃទី៣១ ខែកក្កដា ជារៀងរាល់ឆ្នាំ សម្រាប់អាជ្ញាបណ្ណសវនកម្ម
- ជូនដំណឹងអំពីការមិនបានផ្តល់សេវាគណនេយ្យ ឬសេវាសវនកម្ម ករណីក្រុមហ៊ុនមិនបានផ្តល់សេវារយៈពេល៦(ប្រាំមួយ)ខែ ជាប់ៗគ្នា ដោយបញ្ជាក់ពីមូលហេតុច្បាស់លាស់

- រាយការណ៍ជូនស្ថាប័នមានសមត្ថកិច្ច ក្នុងករណីរកឃើញប្រតិបត្តិការសង្ស័យពាក់ព័ន្ធការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ព្រមទាំងរាយការណ៍ជូនស្ថាប័នមានសមត្ថកិច្ច ឬនិយ័តករពាក់ព័ន្ធ ក្នុងករណីរកឃើញការមិនអនុវត្តតាមច្បាប់និងបទប្បញ្ញត្តិជាធរមានផ្សេងទៀត។

**ប្រការ៣៧ ._**

អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម មិនមែនជាកម្មវត្ថុនៃការលក់ ការផ្ទេរ ឬការដាក់ធានាកាតព្វកិច្ចឡើយ។

## ជំពូកទី៦

## ថ្លៃពាក្យស្នើសុំនិងសោហ៊ុយសិក្សាសំណុំឯកសារ កម្រៃអាជ្ញាបណ្ណ និងសុពលភាពអាជ្ញាបណ្ណ

**ប្រការ៣៨ ._**

នីតិបុគ្គលស្នើសុំ ត្រូវបង់ថ្លៃពាក្យស្នើសុំនិងសោហ៊ុយសិក្សាសំណុំឯកសារ សម្រាប់ការដាក់ពាក្យស្នើសុំអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ ឬអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្ម ជាទឹកប្រាក់សរុបចំនួន២.០០០.០០០ (ពីរលាន)រៀល នៅពេលដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ។

រូបវន្តបុគ្គលស្នើសុំ ត្រូវបង់ថ្លៃពាក្យស្នើសុំនិងសោហ៊ុយសិក្សាសំណុំឯកសារ សម្រាប់ការដាក់ពាក្យស្នើសុំអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ ឬអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្ម ជាទឹកប្រាក់សរុបចំនួន១.០០០.០០០ (មួយលាន)រៀល នៅពេលដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ។

ម្ចាស់អាជ្ញាបណ្ណជានីតិបុគ្គល ត្រូវបង់ថ្លៃពាក្យស្នើសុំនិងសោហ៊ុយសិក្សាសំណុំឯកសារសម្រាប់ការដាក់ពាក្យស្នើសុំបន្តអាជ្ញាបណ្ណ ប្រកបវិជ្ជាជីវៈគណនេយ្យ ឬអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្ម ជាទឹកប្រាក់សរុបចំនួន ១.០០០.០០០(មួយលាន)រៀល នៅពេលដាក់ពាក្យស្នើសុំបន្តអាជ្ញាបណ្ណ។

ម្ចាស់អាជ្ញាបណ្ណជារូបវន្តបុគ្គល ត្រូវបង់ថ្លៃពាក្យស្នើសុំនិងសោហ៊ុយសិក្សាសំណុំឯកសារសម្រាប់ការដាក់ពាក្យស្នើសុំបន្តអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ ឬអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្ម ជាទឹកប្រាក់សរុបចំនួន ៥០០.០០០(ប្រាំរយពាន់)រៀល នៅពេលដាក់ពាក្យស្នើសុំបន្តអាជ្ញាបណ្ណ។

ថ្លៃពាក្យស្នើសុំអាជ្ញាបណ្ណនិងសោហ៊ុយសិក្សាសំណុំឯកសារ ដែលបានបង់មក **ន.គ.ស.** មិនអាចដកវិញបានឡើយ ទោះជាបុគ្គលទទួលបាន ឬមិនទទួលបានអាជ្ញាបណ្ណក៏ដោយ។

**ប្រការ៣៩ ._**

ការបង់កម្រៃអាជ្ញាបណ្ណប្រចាំឆ្នាំពីម្ចាស់អាជ្ញាបណ្ណ ជាការចូលរួមការអភិវឌ្ឍវិស័យនិងវិជ្ជាជីវៈគណនេយ្យនិងសវនកម្មនៅព្រះរាជាណាចក្រកម្ពុជា។ សម្រាប់ឆ្នាំដំបូងម្ចាស់អាជ្ញាបណ្ណជានីតិបុគ្គលប្រកបវិជ្ជាជីវៈគណនេយ្យ ឬប្រកបវិជ្ជាជីវៈសវនកម្ម ត្រូវបង់កម្រៃអាជ្ញាបណ្ណប្រចាំឆ្នាំមក **ន.គ.ស.** ត្រូវបានកំណត់ដូចខាងក្រោម÷

- ចំនួន២.០០០.០០០(ពីរលាន)រៀល សម្រាប់ការស្នើសុំលើកដំបូងមានរយៈពេលច្រើនជាង៦(ប្រាំមួយ)ខែ ធៀបនឹងឆ្នាំចរន្ត។

- ចំនួន១.០០០.០០០(មួយលាន)រៀល សម្រាប់ការស្នើសុំលើកដំបូងមានរយៈពេលតិចជាង៦(ប្រាំមួយ)ខែ ធៀបនឹងឆ្នាំចរន្ត។

សម្រាប់ឆ្នាំបន្តបន្ទាប់ ម្ចាស់អាជ្ញាបណ្ណជានីតិបុគ្គលត្រូវបង់កម្រៃអាជ្ញាបណ្ណប្រចាំឆ្នាំមក **ន.គ.ស.** យ៉ាងយូរត្រឹមថ្ងៃទី៣១ ខែមករា នៃឆ្នាំចរន្តនីមួយៗ។ ពេលវេលាជាក់ស្តែងនៃការបង់កម្រៃអាជ្ញាបណ្ណសម្រាប់ក្រុមហ៊ុននីមួយៗ ត្រូវកំណត់ក្នុងដីកាអមបង់កម្រៃរបស់ **ន.គ.ស.**។ ទំហំទឹកប្រាក់កម្រៃអាជ្ញាបណ្ណប្រចាំ ត្រូវផ្អែកលើតាមចំនួន និយោជិត គិតជាមធ្យមភាគនៃឆ្នាំចុងក្រោយ និងតាមប្រភេទអាជ្ញាបណ្ណដូចខាងក្រោម÷

| ចំនួននិយោជិត | អាជ្ញាបណ្ណគណនេយ្យកម្រិត២ | អាជ្ញាបណ្ណគណនេយ្យកម្រិត១ | អាជ្ញាបណ្ណសវនកម្ម |
|---|---|---|---|
| ១-២០ នាក់ | ២.០០០.០០០ រៀល | ៣.០០០.០០០ រៀល | ៤.០០០.០០០ រៀល |
| ២១-៥០ នាក់ | ៣.០០០.០០០ រៀល | ៤.០០០.០០០ រៀល | ៦.០០០.០០០ រៀល |
| ៥១-១០០ នាក់ | ៤.០០០.០០០ រៀល | ៥.០០០.០០០ រៀល | ១០.០០០.០០០ រៀល |
| ១០១-១៥០នាក់ | ៥.០០០.០០០ រៀល | ៦.០០០.០០០ រៀល | ១៥.០០០.០០០ រៀល |
| ចាប់ពី ១៥១នាក់ឡើងទៅ | ៦.០០០.០០០ រៀល | ៧.០០០.០០០ រៀល | ២០.០០០.០០០ រៀល |

ម្ចាស់អាជ្ញាបណ្ណជានីតិបុគ្គល ត្រូវបង់កម្រៃអាជ្ញាបណ្ណប្រចាំឆ្នាំសម្រាប់រយៈពេលព្យួរ ចំនួន២.០០០.០០០ (ពីរលាន)រៀល ក្នុងមួយឆ្នាំរហូតដល់ពេលទទួលបានការអនុញ្ញាតជាគោលការណ៍ឱ្យប្រកបវិជ្ជាជីវៈឡើងវិញពី **ន.គ.ស.**។

**ប្រការ៤០ ._**

កម្រៃអាជ្ញាបណ្ណប្រចាំឆ្នាំសម្រាប់ឆ្នាំដំបូងចំពោះម្ចាស់អាជ្ញាបណ្ណជារូបវន្តបុគ្គល ដែលទទួលបានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ ឬសវនកម្ម ត្រូវបានកំណត់ ដូចខាងក្រោម÷

- ចំនួន៥០០.០០០(ប្រាំរយពាន់)រៀល សម្រាប់ការស្នើសុំមានរយៈពេលច្រើនជាង៦(ប្រាំមួយ)ខែ ធៀបនឹងឆ្នាំចរន្ត។
- ចំនួន២៥០.០០០(ពីររយហាសិបពាន់)រៀល សម្រាប់ការស្នើសុំមានរយៈពេលតិចជាង៦(ប្រាំមួយ)ខែ ធៀបនឹងឆ្នាំចរន្ត។

កម្រៃអាជ្ញាបណ្ណប្រចាំឆ្នាំ សម្រាប់ឆ្នាំបន្តបន្ទាប់ចំពោះម្ចាស់អាជ្ញាបណ្ណជារូបវន្តបុគ្គលដែលទទួលបានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យត្រូវបានកំណត់ចំនួន៥០០.០០០ (ប្រាំរយពាន់)រៀល និងអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្ម ត្រូវបានកំណត់ចំនួន៧០០.០០០ (ប្រាំពីររយពាន់)រៀល ។

សម្រាប់ឆ្នាំបន្ទាប់ ម្ចាស់អាជ្ញាបណ្ណជារូបវន្តបុគ្គល ត្រូវបង់កម្រៃអាជ្ញាបណ្ណប្រចាំឆ្នាំមក **ន.គ.ស.** យ៉ាងយូរត្រឹមថ្ងៃទី៣១ ខែមករា នៃឆ្នាំនីមួយៗ។

ម្ចាស់អាជ្ញាបណ្ណជារូបវន្តបុគ្គល ត្រូវបង់កម្រៃអាជ្ញាបណ្ណប្រចាំឆ្នាំសម្រាប់រយៈពេលព្យួរ ចំនួន៥០០.០០០ (ប្រាំរយពាន់)រៀល ក្នុងមួយឆ្នាំ រហូតដល់ពេលទទួលបានការអនុញ្ញាតជាគោលការណ៍ឱ្យប្រកបវិជ្ជាជីវៈឡើងវិញពី **ន.គ.ស.**។

**ប្រការ៤១ ._**

ម្ចាស់អាជ្ញាបណ្ណ ត្រូវមកទទួលយកដីកាអមបង់កម្រៃអាជ្ញាបណ្ណប្រចាំឆ្នាំពី **ន.គ.ស.** ឱ្យបានមុនថ្ងៃផុតកំណត់នៃការបង់កម្រៃអាជ្ញាបណ្ណ ដោយភ្ជាប់មកជាមួយនូវសន្លឹកអាជ្ញាបណ្ណ។

សុពលភាពនៃអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ ឬអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្ម មានរយៈពេល៣ (បី)ឆ្នាំ។ យ៉ាងតិច៤៥(សែសិបប្រាំ)ថ្ងៃ មុនសុពលភាពអាជ្ញាបណ្ណផុតកំណត់ ម្ចាស់អាជ្ញាបណ្ណដែលមានបំណងបន្តការប្រកបវិជ្ជាជីវៈ ត្រូវដាក់ពាក្យស្នើសុំតាមទម្រង់ដែលកំណត់ដោយ **ន.គ.ស.**។ ក្នុងករណីមានការយឺតយ៉ាវ ម្ចាស់អាជ្ញាបណ្ណនឹងទទួលរងទោសទណ្ឌ ដូចមានចែងក្នុងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។ ក្នុងករណីមិនគោរពតាមរយៈពេលដែលមានចែងក្នុងកថាខណ្ឌខាងលើ **ន.គ.ស.** មានសិទ្ធិមិនទទួលពាក្យស្នើសុំអាជ្ញាបណ្ណ។

## ជំពូកទី៧

## ការព្យួរអាជ្ញាបណ្ណ

**ប្រការ៤២ ._**

ម្ចាស់អាជ្ញាបណ្ណជានីតិបុគ្គល ឬរូបវន្តបុគ្គល អាចដាក់ពាក្យស្នើសុំព្យួរអាជ្ញាបណ្ណដោយស្ម័គ្រចិត្តបាន ក្នុងករណីមានមូលហេតុសមស្រប ដោយមិនមែនជាមូលហេតុនៃការគេចវេះពីកាតព្វកិច្ច។

ម្ចាស់អាជ្ញាបណ្ណជានីតិបុគ្គល ឬរូបវន្តបុគ្គលត្រូវដាក់ពាក្យស្នើសុំមក **ន.គ.ស.** និងបញ្ជាក់អំពីមូលហេតុសមស្រប ដោយត្រូវបង្ហាញភស្តុតាងនានាដែលបញ្ជាក់ថាខ្លួនបានបំពេញកាតព្វកិច្ចនានារួចរាល់ជាមួយអតិថិជន ឬបានចុះកិច្ចព្រមព្រៀងជាមួយក្រុមហ៊ុនគណនេយ្យ និង/ឬក្រុមហ៊ុនសវនកម្មផ្សេងទៀត ដើម្បីផ្ទេរអតិថិជន និងបានបំពេញកាតព្វកិច្ចជាមួយស្ថាប័នពាក់ព័ន្ធចប់សព្វគ្រប់។ **ន.គ.ស.** ត្រូវឆ្លើយតបជាលាយលក្ខណ៍អក្សរទៅម្ចាស់អាជ្ញាបណ្ណក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការគិតចាប់ពីថ្ងៃទទួលបានពាក្យស្នើសុំ និងឯកសារពេញលេញ។

**ប្រការ៤៣ ._**

ម្ចាស់អាជ្ញាណ្ណជានីតិបុគ្គល អាចត្រូវបានព្យួរអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ និង/ឬសវនកម្មដោយមូលហេតុណាមួយដូចខាងក្រោម÷

- ចំណែកភាគហ៊ុនរបស់សមាជិកសកម្ម ឬសមាជិកចូលរួម ឬសមាជិកសមាគត បានធ្លាក់ចុះក្រោម៥១% (ហាសិបមួយភាគរយ) សម្រាប់ក្រុមហ៊ុនគណនេយ្យ ឬសវនកម្ម ដែលមានម្ចាស់ភាគហ៊ុនរូបវន្តបុគ្គល
- ចំនួនសមាជិកកម្ម ឬសមាជិកចូលរួម ឬសមាជិកសមាគត របស់ **វ.គ.ស.ក.** ដែលមានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យឬសវនកម្ម ពី **ន.គ.ស.** ជាសមាសភាពក្រុមប្រឹក្សាភិបាល បានធ្លាក់ចុះក្រោម ៥០%បូក១(ហាសិបភាគរយបូកមួយ) សម្រាប់ក្រុមហ៊ុនគណនេយ្យ ឬសវនកម្ម ដែលមានម្ចាស់ភាគហ៊ុនជានីតិបុគ្គល

- បានប្រព្រឹត្តកំហុសធ្ងន់ធ្ងរលើជំនាញ និងក្រមសីលធម៌វិជ្ជាជីវៈជាច្រើនដងដែលផ្ទុយនឹងផលប្រយោជន៍សាធារណៈ ឬធ្វើឱ្យប៉ះពាល់ដល់វិជ្ជាជីវៈគណនេយ្យនិងសវនកម្ម ក្រោយពីទទួលបានបណ្តឹងពីអ្នក ពាក់ព័ន្ធ និងដោយមានការបញ្ជាក់ជាលាយលក្ខណ៍អក្សរពី **វ.គ.ស.ក.**
- មិនគោរពឱ្យបានខ្ជាប់ខ្ជួននូវកាតព្វកិច្ចនានា ដូចបានកំណត់នៅក្នុងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធ ដែលផ្ទុយទៅនឹងផលប្រយោជន៍សាធារណៈ ឬធ្វើឱ្យប៉ះពាល់ដល់វិជ្ជាជីវៈគណនេយ្យនិងសវនកម្ម
- យឺតយ៉ាវក្នុងការបង់កម្រៃអាជ្ញាបណ្ណប្រចាំឆ្នាំ រយៈពេល៣០(សាមសិប)ថ្ងៃ គិតពីថ្ងៃទទួលបានការជូនដំណឹងពី **ន.គ.ស.**
- ទទួលបានសេចក្តីសម្រេចព្យួរ ឬដកហូតសមាជិកភាពពី **វ.គ.ស.ក.**
- បានទទួលសំណើ និងបានពិនិត្យលើសំណើសុំព្យួរអាជ្ញាបណ្ណពីស្ថាប័នមានសមត្ថកិច្ចដទៃទៀត
- កំពុងស្ថិតនៅក្នុងដំណើរការនីតិវិធីតុលាការក្នុងនាមជាជនត្រូវចោទពីបទមជ្ឈិមឬបទឧក្រិដ្ឋដោយតុលាការនៃព្រះរាជាណាចក្រកម្ពុជា ឬដែនសមត្ថកិច្ចប្រទេសពាក់ព័ន្ធផ្សេងៗ។

ក្នុងករណីមានមូលហេតុណាមួយក្នុងចំណោមមូលហេតុខាងលើ **ន.គ.ស.** ត្រូវចេញសេចក្តីសម្រេចព្យួរអាជ្ញាបណ្ណ តាមរយៈការជូនដំណឹងជាលាយលក្ខណ៍អក្សរ ដោយបញ្ជាក់ពីរយៈពេលនៃការព្យួរដល់ម្ចាស់អាជ្ញាបណ្ណ និងផ្សព្វផ្សាយជាសាធារណៈ ក្រោយការចេញសេចក្តីសម្រេច។

**ន.គ.ស.** អាចតម្រូវឱ្យម្ចាស់អាជ្ញាបណ្ណបំពេញកាតព្វកិច្ចនានាឱ្យបានរួចរាល់ជាមួយអតិថិជន ក្នុងអំឡុងពេលណាមួយជាក់លាក់ ឬតម្រូវឱ្យម្ចាស់អាជ្ញាបណ្ណចុះកិច្ចព្រមព្រៀងជាមួយក្រុមហ៊ុនគណនេយ្យ ឬក្រុមហ៊ុនសវនកម្មផ្សេងទៀតដើម្បីផ្ទេរអតិថិជននិងការងារ និងតម្រូវឱ្យបំពេញកាតព្វកិច្ចជាមួយស្ថាប័នពាក់ព័ន្ធចប់សព្វគ្រប់។

ម្ចាស់អាជ្ញាបណ្ណជានីតិបុគ្គលអាចស្នើសុំមក **ន.គ.ស.** ដើម្បីលុបសេចក្តីសម្រេចព្យួរអាជ្ញាបណ្ណ ក្នុងករណីមូលហេតុនៃការព្យួរអាជ្ញាបណ្ណត្រូវបានដោះស្រាយរួចរាល់។

**ប្រការ៤៤**._

ម្ចាស់អាជ្ញាបណ្ណជារូបវន្តបុគ្គល អាចត្រូវបានព្យួរអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ និង/ឬសវនកម្មដោយមូលហេតុណាមួយដូចខាងក្រោម÷

- បានប្រព្រឹត្តកំហុសធ្ងន់ធ្ងរនិងជាច្រើនដងដែលផ្ទុយទៅនឹងផលប្រយោជន៍សាធារណៈ ឬធ្វើឱ្យប៉ះពាល់ដល់វិជ្ជាជីវៈគណនេយ្យនិងសវនកម្ម
- មិនគោរពនិងអនុវត្តតាមក្រមសីលធម៌វិជ្ជាជីវៈ និងស្តង់ដាបច្ចេកទេសពាក់ព័ន្ធជាធរមានដែលផ្ទុយទៅនឹងផលប្រយោជន៍សាធារណៈ ឬធ្វើឱ្យប៉ះពាល់ដល់វិជ្ជាជីវៈគណនេយ្យនិងសវនកម្ម
- បានបំពានកាតព្វកិច្ចណាមួយតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន
- ទទួលបានសេចក្តីសម្រេចព្យួរ ឬដកហូតសមាជិកភាពពី **វ.គ.ស.ក.**
- យឺតយ៉ាវក្នុងការបង់កម្រៃអាជ្ញាបណ្ណប្រចាំឆ្នាំ រយៈពេល៣០(សាមសិប)ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃទទួលបានការជូនដំណឹងពី **ន.គ.ស.**
- បានទទួលសំណើ និងបានពិនិត្យលើសំណើសុំព្យួរអាជ្ញាបណ្ណពីស្ថាប័នមានសមត្ថកិច្ចដទៃទៀត

- កំពុងស្ថិតនៅក្នុងដំណើរការនីតិវិធីតុលាការក្នុងនាមជាជនត្រូវចោទពីបទមជ្ឈិមឬបទឧក្រិដ្ឋដោយតុលាការនៃព្រះរាជាណាចក្រកម្ពុជា ឬដែនសមត្ថកិច្ចប្រទេសពាក់ព័ន្ធផ្សេងៗ។

ក្នុងករណីមានមូលហេតុណាមួយក្នុងចំណោមមូលហេតុខាងលើ **ន.គ.ស.** ត្រូវចេញសេចក្តីសម្រេចព្យួរអាជ្ញាបណ្ណ តាមរយៈការជូនដំណឹងជាលាយលក្ខណ៍អក្សរ ដោយបញ្ជាក់ពីរយៈពេលនៃការព្យួរដល់ម្ចាស់អាជ្ញាបណ្ណ និងផ្សព្វផ្សាយជាសាធារណៈក្រោយការចេញសេចក្តីសម្រេច។

**ន.គ.ស.** អាចតម្រូវឱ្យម្ចាស់អាជ្ញាបណ្ណបំពេញកាតព្វកិច្ចនានាឱ្យបានរួចរាល់ជាមួយអតិថិជន ក្នុងអំឡុងពេលណាមួយជាក់លាក់ ឬតម្រូវឱ្យម្ចាស់អាជ្ញាបណ្ណចុះកិច្ចព្រមព្រៀងជាមួយក្រុមហ៊ុនគណនេយ្យ ឬក្រុមហ៊ុនសវនកម្មផ្សេងទៀតដើម្បីផ្ទេរអតិថិជននិងការងារ និងតម្រូវឱ្យបំពេញកាតព្វកិច្ចជាមួយស្ថាប័នពាក់ព័ន្ធចប់សព្វគ្រប់។

ម្ចាស់អាជ្ញាបណ្ណជារូបវន្តបុគ្គល អាចស្នើសុំមក **ន.គ.ស.** ដើម្បីលុបសេចក្តីសម្រេចព្យួរអាជ្ញាបណ្ណ ក្នុងករណីមូលហេតុនៃព្យួរអាជ្ញាបណ្ណត្រូវបានដោះស្រាយរួចរាល់។

## ជំពូកទី ៨

## ការដកហូតអាជ្ញាបណ្ណ

**ប្រការ៤៥ ._**

ម្ចាស់អាជ្ញាបណ្ណជានីតិបុគ្គល អាចត្រូវបានដកហូតអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ និង/ឬសវនកម្មដោយមូលហេតុណាមួយដូចខាងក្រោម÷

- បានប្រព្រឹត្តបទឧក្រិដ្ឋដោយមានសេចក្តីសម្រេចស្ថាពរពីតុលាការ
- បានបាត់បង់សមាជិកភាពពី **វ.គ.ស.ក.** ដោយមានលិខិតជូនដំណឹងពី **វ.គ.ស.ក.**
- ផុតកាលអវសាននៃការព្យួរដោយស្ម័គ្រចិត្តហើយម្ចាស់អាជ្ញាបណ្ណមិនមកដាក់ពាក្យសុំបន្តអាជ្ញាបណ្ណ
- មូលហេតុនៃការព្យួរដោយបង្ខំនៅមិនទាន់ត្រូវបានដោះស្រាយក្នុងរយៈពេលដែលបានកំណត់នៅក្នុងលិខិតជូនដំណឹងរបស់ **ន.គ.ស.**
- មានបណ្តឹងពីអតិថិជន ឬស្ថាប័នមានសមត្ថកិច្ចមក **ន.គ.ស.** ដោយពិនិត្យឃើញថាមានកំហុសធ្ងន់ធ្ងរ
- បំពានទៅនឹងមាត្រា១៥ នៃច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម
- ប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា៣៥ នៃច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម
- ទទួលបានអាជ្ញាបណ្ណ តែមិនបានផ្តល់សេវារយៈពេល១២(ដប់ពីរ)ខែ ជាប់ៗគ្នា គិតពីកាលបរិច្ឆេទចេញអាជ្ញាបណ្ណ ដោយមិនបានដាក់ពាក្យសុំព្យួរ
- ម្ចាស់អាជ្ញាបណ្ណ ដាក់ពាក្យបញ្ឈប់ការប្រកបវិជ្ជាជីវៈដោយខ្លួនឯង។

ក្នុងករណីមានមូលហេតុណាមួយខាងលើ **ន.គ.ស.** ត្រូវពិនិត្យ និងសម្រេចដកហូតអាជ្ញាបណ្ណដោយ **ន.គ.ស.** ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ម្ចាស់អាជ្ញាបណ្ណ និងផ្សព្វផ្សាយជាសាធារណៈក្រោយការចេញសេចក្តីសម្រេច។

**ប្រការ៤៦ ._**

ម្ចាស់អាជ្ញាបណ្ណជារូបវន្តបុគ្គល អាចត្រូវបានដកហូតអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ និង/ឬសវនកម្មដោយមូលហេតុណាមួយដូចខាងក្រោម÷

- ទទួលរងការផ្តន្ទាទោសជាប់ពន្ធនាគារនិងត្រូវអនុវត្តទោសក្នុងពន្ធនាគារ ពីបទឧក្រិដ្ឋណាមួយ ឬទទួលរងការផ្តន្ទាទោសជាប់ពន្ធនាគារតាមស្មារតីនៃច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ឬច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន
- បានបាត់បង់សមាជិកភាពពី **វ.គ.ស.ក.** ដោយមានលិខិតជូនដំណឹងពី **វ.គ.ស.ក.**
- ផុតកាលអវសាននៃការព្យួរដោយស្ម័គ្រចិត្តនិងម្ចាស់អាជ្ញាបណ្ណមិនមកដាក់ពាក្យសុំបន្តអាជ្ញាបណ្ណ
- មូលហេតុនៃការព្យួរដោយបង្ខំនៅមិនទាន់ត្រូវបានដោះស្រាយក្នុងរយៈពេលដែលបានកំណត់នៅក្នុងលិខិតជូនដំណឹងរបស់ **ន.គ.ស.**
- ការបំពានទៅនឹងមាត្រា១៥ ឬកថាខណ្ឌទី២នៃមាត្រា២៨ ឬមាត្រា៣៥ នៃច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម
- មានពិការភាពផ្នែកស្មារតី ឬកាយសម្បទាធ្ងន់ធ្ងរប៉ះពាល់ដល់ការផ្តល់សេវាគណនេយ្យ និង/ឬសវនកម្ម
- ទទួលបានអាជ្ញាបណ្ណ តែមិនបានផ្តល់សេវារយៈពេល១២(ដប់ពីរ)ខែ ជាប់ៗគ្នា គិតពីកាលបរិច្ឆេទចេញអាជ្ញាបណ្ណ ដោយមិនបានដាក់ពាក្យសុំព្យួរ
- ម្ចាស់អាជ្ញាបណ្ណ ដាក់ពាក្យបញ្ឈប់ការប្រកបវិជ្ជាជីវៈដោយខ្លួនឯង។

ក្នុងករណីមានមូលហេតុណាមួយខាងលើ **ន.គ.ស.** ត្រូវពិនិត្យ និងសម្រេចដកហូតអាជ្ញាបណ្ណដោយ **ន.គ.ស.** ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ម្ចាស់អាជ្ញាបណ្ណនិងផ្សព្វផ្សាយជាសាធារណៈក្រោយការចេញសេចក្តីសម្រេច។

## ជំពូកទី៩
## បទប្បញ្ញត្តិផ្សេងៗ

**ប្រការ៤៧ ._**

ក្រោយទទួលបានអាជ្ញាបណ្ណ ម្ចាស់អាជ្ញាបណ្ណអាចទទួលរងការត្រួតពិនិត្យពី **ន.គ.ស.** ក្នុងក្របខណ្ឌនៃការអនុវត្តកាតព្វកិច្ចតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន និងការត្រួតពិនិត្យគុណភាពសវនកម្ម ដែលនឹងត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.**។

ក្រុមហ៊ុនគណនេយ្យ និង/ឬសវនកម្ម ត្រូវផ្តល់គ្រប់មធ្យោបាយ ដើម្បីឱ្យ **ន.គ.ស.** អាចគ្រប់គ្រង ឃ្លាំមើល និងត្រួតពិនិត្យរាល់សកម្មភាពផ្តល់សេវារបស់ក្រុមហ៊ុន ក្នុងករណីចាំបាច់។

**ន.គ.ស.** ត្រូវចាត់ចែងការចុះត្រួតពិនិត្យដល់ទីកន្លែងដើម្បីផ្ទៀងផ្ទាត់ពាក្យស្នើសុំអាជ្ញាបណ្ណ ឬការអនុញ្ញាត និងដើម្បីធ្វើការត្រួតពិនិត្យនូវរាល់ព័ត៌មាន ទិន្នន័យ ឯកសារ និងប្រតិបត្តិការពាក់ព័ន្ធនឹងសេវាកម្មរបស់ម្ចាស់អាជ្ញាបណ្ណ។

**ប្រការ៤៨ ._**

**ន.គ.ស.** អាចដាក់ចេញវិធានចាំបាច់នានា ដើម្បីពង្រឹងការគ្រប់គ្រងនិងត្រួតពិនិត្យ។

## ជំពូកទី១០
## វិធានការរដ្ឋបាល និងទោសប្បញ្ញត្តិ

**ប្រការ៤៩ ._**

ម្ចាស់អាជ្ញាបណ្ណប្រព្រឹត្តល្មើសនឹងប្បញ្ញត្តិណាមួយនៃប្រកាសនេះ **ន.គ.ស.** អាចចាត់វិធានការរដ្ឋបាលនានាដូចខាងក្រោម÷

- ការព្រមាន
- ការដឹកនាំកែតម្រង់
- ការដាក់កំហិតលើការផ្តល់សេវា
- ការស្តីបន្ទោសផ្ទាល់មាត់
- ការស្តីបន្ទោសដោយមានចំណារក្នុងសំណុំលិខិតផ្ទាល់ខ្លួន។

**ប្រការ៥០ ._**

ការប្រកបវិជ្ជាជីវៈ ដោយគ្មានអាជ្ញាបណ្ណ ត្រូវរងទោសទណ្ឌដូចបានកំណត់ក្នុងមាត្រា៣៣ និងមាត្រា៣៤ នៃច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម។ ការប្រកបវិជ្ជាជីវៈគណនេយ្យ ឬការប្រកបវិជ្ជាជីវៈសវនកម្ម ក្រោមអាជ្ញាបណ្ណផុតសុពលភាព ត្រូវបានចាត់ទុកថាជាការប្រកបវិជ្ជាជីវៈដោយគ្មានអាជ្ញាបណ្ណ។

## ជំពូកទី១១
## គណនេយ្យករនិងសវនករជាជនបរទេស

**ប្រការ៥១ ._**

ការប្រកបវិជ្ជាជីវៈគណនេយ្យ ឬសវនកម្ម សម្រាប់គណនេយ្យករនិងសវនករជាជនបរទេស ត្រូវកំណត់ដោយប្រកាសនិងបទប្បញ្ញត្តិដោយឡែក។

ករណីមិនទាន់មានការកំណត់បទប្បញ្ញត្តិដោយឡែក ថ្លៃពាក្យស្នើសុំនិងសោហ៊ុយសិក្សាសំណុំឯកសារ និងកម្រៃអាជ្ញាបណ្ណ សម្រាប់គណនេយ្យករនិងសវនករជាជនបរទេស ត្រូវអនុវត្តតាមប្រកាសនេះ។

## ជំពូកទី១២
## អន្តរប្បញ្ញត្តិ

**ប្រការ៥២ ._**

គណនេយ្យករ ឬសវនករជារូបវន្តបុគ្គលដែលបានទទួលការអនុញ្ញាតពី **ន.គ.ស.** ក្នុងការបើកក្រុមហ៊ុនគណនេយ្យ ឬក្រុមហ៊ុនសវនកម្ម ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ ឬសវនកម្ម សម្រាប់រូបវន្តបុគ្គល ក្នុងរយៈពេល៩០(កៅសិប)ថ្ងៃ ក្រោយការចូលជាធរមាននៃប្រកាសនេះដោយត្រូវអនុវត្តលក្ខខណ្ឌពាក់ព័ន្ធដែលមាន ចែងក្នុងប្រកាសនេះ។

**ប្រការ៥៣ ._**

ក្រុមហ៊ុនដែលកំពុងផ្តល់សេវាកម្មគណនេយ្យ ឬសវនកម្ម ដែលមិនមានអាជ្ញាបណ្ណឬការអនុញ្ញាតពី **ន.គ.ស.** ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យក្នុងរយៈពេល៩០(កៅសិប)ថ្ងៃយ៉ាងយូរ ក្រោយការចូលជាធរមាននៃប្រកាសនេះ ដោយត្រូវអនុវត្តលក្ខខណ្ឌពាក់ព័ន្ធដែលមានចែងក្នុងប្រកាសនេះ។

**ប្រការ៥៤ ._**

ការអនុញ្ញាតប្រកបវិជ្ជាជីវៈគណនេយ្យ ឬសវនកម្ម ដែលផ្តល់ដោយ **ន.គ.ស.** មុនពេលដាក់ឱ្យអនុវត្តប្រកាសនេះ នៅបន្តមានសុពលភាពរហូតដល់ផុតសុពលភាពនៃការអនុញ្ញាតនោះ។ ដោយឡែកការបង់កម្រៃអាជ្ញាបណ្ណប្រចាំឆ្នាំចំពោះនីតិបុគ្គល ត្រូវអនុវត្តចាប់ពីការិយបរិច្ឆេទឆ្នាំ២០២៣ តទៅ។

**ប្រការ៥៥ ._**

ប្រកាសលេខ១០៣ សហវ.ប្រក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០ ស្តីពីការអនុញ្ញាតឱ្យគណនេយ្យករជំនាញ និងសវនករប្រតិស្រុតជាជនបរទេស មានសិទ្ធិបន្តចុះហត្ថលេខាលើរបាយការណ៍គណនេយ្យ និងរបាយការណ៍សវនកម្ម បន្តមានសុពលភាពអនុវត្ត រហូតដល់មានបទប្បញ្ញត្តិថ្មីមកជំនួស។

## ជំពូកទី១៣

## អវសានប្បញ្ញត្តិ

**ប្រការ៥៦ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥៧ ._**

អគ្គនាយកនៃ **ន.គ.ស.** ប្រធានក្រុមប្រឹក្សាភិបាល **ទ.គ.ស.ក.** ប្រធាននាយកដ្ឋានគ្រប់គ្រងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម គ្រប់ប្រធាននាយកដ្ឋានស្ថិតក្រោមចំណុះ **ន.គ.ស.** និងបុគ្គលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ព្រហស្បតិ៍ ១ កើត ខែ ពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មេសា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ឯកឧត្តម លោកជំទាវជាអនុប្រធាន និងសមាជិកក្រុមប្រឹក្សា-អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៥៧

  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ